**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្ត**
**សៀមរាប-ឧត្តរមានជ័យ**
សាលក្រម
លេខ ០៥ ខ ចុះថ្ងៃទី ២៨
ខែ កុម្ភៈ ឆ្នាំ ២០០៦
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥១១ ចុះថ្ងៃទី ៣១
ខែ សីហា ឆ្នាំ ២០០៥

នាមប្រជារាស្ត្រខ្មែរ

**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ៥១១ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

-ឈ្មោះ ត ចន ភេទស្រី អាយុ ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិប្រាសាទ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៣ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិប្រាសាទ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប របររកស៊ីនៅផ្ទះ ។ប្តីឈ្មោះ **សរ ស** (ស) មានកូន០៣នាក់ ឪពុកឈ្មោះ **ស ញ** (រ) ម្តាយឈ្មោះ **យ ទ** (រ) ទោសពីមុន *គ្មាន* ។

ឃុំខ្លួនថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ **ទិញលក់រក្សាទុកគ្រឿងញៀន ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ** ប្រព្រឹត្តនៅភូមិប្រាសាទ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប ។

កាលពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី កថាខណ្ឌទី ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

ឈ្មោះ ត ចន រស់នៅភូមិប្រាសាទ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប បាននាំប្តីមករស់នៅឃុំប៉ោយប៉ែត មុខរបរធ្វើកម្មករនៅក្នុងកាស៊ីណូបានស្គាល់ឈ្មោះ

*សាលក្រមនេះបានចូលជាស្ថាពរនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦*
*ដោយពុំមានគូភាគីណាមួយចូលមកប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ឡើយ ។*
*សៀមរាប.ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
*ក្រឡាបញ្ជី*
*ហត្ថលេខា និង ត្រា*
[redacted]

ទិន ភេទប្រុស នៅភូមិប្រជាធម្ម ឃុំប៉ោយប៉ែត ជាអ្នកជក់ថ្នាំញៀន តែក្រោយមកឈ្មោះ ត ចន មានផ្ទុកមេរោគអេដស៍ត្រូវគេបញ្ឈប់ពីការងារក្នុងឆ្នាំ ២០០៥ ឈ្មោះ ត ចន បានត្រឡប់មករកស៊ីនៅស្រុកកំណើតវិញ បានជួបនឹងក្មេងៗជក់ថ្នាំញៀនចេះតែសួរនៅប៉ោយប៉ែតថា មានថ្នាំញៀនលក់ទេ ពួកគេទិញក្នុង ០១គ្រាប់តម្លៃ ៨.០០០រៀល ( ប្រាំបីពាន់រៀល) ឈ្មោះ ត ចន ក៏មានគំនិតលក់ចែកចាយថ្នាំញៀនតែម្តង ។

នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ ឈ្មោះ ត ចន បានជិះឡានឈ្នួលទៅប៉ោយប៉ែតទៅស្នាក់នៅផ្ទះឈ្មោះ ឡុំ ទៅរកឈ្មោះ ទិន ឱ្យទៅជួយរកទិញថ្នាំញៀន ពេលនោះឈ្មោះ ទិន បានទៅទិញមិនដឹងជាកន្លែងណាទេ បានថ្នាំចំនួន ៣០គ្រាប់ ក្នុង ០១គ្រាប់តម្លៃ ៣៥បាត ឈ្មោះ ត ចន បានយកថ្នាំនោះមកលក់ឱ្យក្មេងៗមិនស្គាល់ឈ្មោះនៅភូមិប្រាសាទក្នុង ០១គ្រាប់តម្លៃ ៨.០០០រៀល ( ប្រាំបីពាន់រៀល) អស់ចំនួន ៣០គ្រាប់ ។

នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ ឈ្មោះ ត ចន បានទៅប៉ោយប៉ែតទៅឱ្យឈ្មោះ ទិន ទិញថ្នាំញៀនឱ្យចំនួន ១០០គ្រាប់ ក្នុង ០១គ្រាប់តម្លៃ ៣៥បាតដដែល ឈ្មោះ ត ចន បានជិះឡានត្រឡប់មកដល់ស្រុកវិញដាក់ថ្នាំក្នុងហោប៉ៅខោខូវប៊ូយព្យួរនឹងស្នូរមិនបានយកមកលក់ទេ នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ត្រូវសមត្ថកិច្ចធ្វើការឆែកឆេរនៅផ្ទះភូមិប្រាសាទ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប ឃើញថ្នាំញៀនចំនួន ១០០គ្រាប់ ក្រោយលទ្ធផលកោសល្យវិច័យនៅសល់ចំនួន ៩០គ្រាប់ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ត ចន បានឆ្លើយថា កាលពីឆ្នាំ ២០០០ ខ្លួនបានទៅធ្វើការកាស៊ីណូនៅប៉ោយប៉ែតបានរយៈពេល ០១ឆ្នាំក៏បានឈប់ ហើយរកស៊ីលក់ផ្លែឈើនៅផ្សារប៉ោយប៉ែត រហូតដល់ប្តីរបស់ខ្លួនស្លាប់ទៅ ទើបខ្លួនត្រឡប់មករស់នៅស្រុកកំណើតជាមួយម្តាយវិញ ។ កាលពីនៅប៉ោយប៉ែតខ្លួនបានស្គាល់ឈ្មោះ ទិន ត្រូវជាមិត្តភក្តិរបស់ប្តី ធ្លាប់ឃើញឈ្មោះ ទិន ជក់ថ្នាំញៀន ពេលដែលខ្លួនមកដល់ស្រុកវិញ បានជួបក្មេងៗជក់ថ្នាំញៀនពួកវាចេះតែសួរខ្លួនថា នៅប៉ោយប៉ែតមានថ្នាំញៀនលក់ទេ ខ្លួនបានឆ្លើយថា ធ្លាប់ស្គាល់គេចេះជក់ដែរ ក្មេងៗនិយាយថា រកស៊ីថ្នាំញៀនចំណេញណាស់ ។

នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ ខ្លួនបានជិះឡានទៅប៉ោយប៉ែតទៅស្នាក់នៅផ្ទះឈ្មោះ ឡុំ រួចបានទៅរកឈ្មោះ ទិន នៅភូមិប្រជាធម្ម ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ជាអ្នករកស៊ីលក់ត្រីនៅផ្សារថៃ ឈ្មោះ ទិន មិនបានឱ្យខ្លួនទៅទិញដល់កន្លែងទេ ឱ្យនៅចាំយកនឹងផ្ទះគេ ដោយយកមកលក់ឱ្យខ្លួនក្នុង ០១គ្រាប់ តម្លៃ ៣៥បាត ខ្លួនទិញលើកទី១ បានចំនួន ៣០គ្រាប់ ខ្លួនយកមកដល់ផ្ទះបានលក់ឱ្យក្មេងៗមិនស្គាល់ឈ្មោះបានតម្លៃក្នុង ០១គ្រាប់ ៨.០០០រៀល ( ប្រាំបីពាន់រៀល) រហូតដល់អស់ ។

នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ ខ្លួនបានជិះឡានទៅប៉ោយប៉ែតម្តងទៀតទៅស្នាក់នៅផ្ទះឈ្មោះ ឡុំ ទៀត រួចបានឱ្យឈ្មោះ ទ ទិញថ្នាំញៀនឱ្យម្តងទៀតបានចំនួន ១០០គ្រាប់ក្នុងតម្លៃដដែល ហើយបានជិះឡានត្រឡប់មកផ្ទះវិញមិនបានយកថ្នាំញៀនទៅលក់ទេ ដឹងថាក្មេងៗទៅប្តឹងសមត្ថកិច្ចខ្លួនបានយកថ្នាំទៅលាក់ទុកនឹងហោប៉ៅខោខូវប៊ូយព្យួរនៅបៀតជញ្ជាំង រយៈពេលជាងដប់ថ្ងៃត្រូវសមត្ថកិច្ចធ្វើការឆែកឆេរផ្ទះរកឃើញថ្នាំញៀនតែម្តង ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

ឆ្លងតាមការសួរដេញដោល និង ចម្លើយសារភាពរបស់ជនជាប់ចោទរួចមកឃើញថា ឈ្មោះ ត ចន ពិតពិតជាបានទិញថ្នាំញៀនពីឈ្មោះ ទិន យកមកលក់ឱ្យក្មេងៗក្នុងភូមិរបស់ខ្លួនរហូតដល់សមត្ថកិច្ចចាប់ខ្លួនតែម្តង ។

មានពិរុទ្ធភាពចួនល្មមលើឈ្មោះ ត ចន ពីបទទិញលក់រក្សាទុកគ្រឿងញៀនដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តនៅភូមិប្រាសាទ ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ ។

ហេតុនេះសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៨៦ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៦ ទុកជាបានការពេញទាំងមូល ។

សូមតុលាការផ្ដន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ៣៣ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

ជនជាប់ចោទឈ្មោះ ត ចន បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-បានស្ដាប់ចម្លើយជនជាប់ចោទ

-បានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-បានស្ដាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**<u>តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ</u>**

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-កាលពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ ឈ្មោះ ត ចន បានទិញថ្នាំញៀនពីឈ្មោះ ខ ចំនួន ៣០គ្រាប់ និង នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ ទិញចំនួន ១០០គ្រាប់ ក្នុងមួយគ្រាប់តម្លៃ ៣៥បាត បានលក់ទៅឱ្យក្មេង១អស់ចំនួន ៣០គ្រាប់ ក្នុង ០១គ្រាប់តម្លៃ ៨.០០០រៀលនៅសល់ថ្នាំញៀនចំនួន ១០០គ្រាប់ទៀត បានយកទៅលាក់ទុកនឹងហោប៉ៅខោព្យួរកៀនជញ្ជាំង ត្រូវបានសមត្ថកិច្ចរកឃើញឃាត់ខ្លួនតែម្ដង ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ ត ចន មានចែង និង ផ្ដន្ទាទោសតាមមាត្រា ៣៣ថ្មី កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

-ប៉ុន្តែបើពិនិត្យឱ្យជិតដល់ទៅឃើញថា ជនជាប់ចោទឈ្មោះ ត ចន ស្ថិតនៅក្នុងយុវវ័យខ្វះការពិចារណាជីវភាពក្រលំបាក ហើយទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។

-វត្ថុតាងមានថ្នាំគ្រាប់ចំនួន ១០០គ្រាប់ គឺពិតជាថ្នាំញៀនមានឈ្មោះមេតំហ្វេតាមីន និង ជាតិកាហ្វេអីន (ហៅក្រៅថា យ៉ាបា ឬ ថ្នាំឆ្កួត) មានទម្ងន់សរុបស្មើនឹង ៨.៨៧៣ក្រាម ដែលជាសារធាតុប៉ះពាល់ដល់ប្រព័ន្ធប្រសាទស្ថិតក្នុងតារាងទី ២ នៃឧបសម្ព័ន្ធច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**<u>ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្ដី</u>**

១-ផ្ដន្ទាទោសឈ្មោះ ត ចន ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ **ទិញលក់រក្សាទុកគ្រឿងញៀន** ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ តាមមាត្រា ៣៣ថ្មី កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ប្រព្រឹត្តនៅភូមិប្រាសាទ ឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប កាលពីថ្ងៃទី ០១ ដល់ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ ។

២-វត្ថុតាងមានថ្នាំញៀនប្រភេទមេតំហ្វេតាមីនចំនួន ៩០គ្រាប់ ( កៅសិបគ្រាប់) ត្រូវរឹបអូសបំផ្លាញចោល ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា**
[redacted]

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**
[redacted]